ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍ត្រួតពិនិត្យ

# ប្រចាំឆ្នាំ ២០២០

អគ្គនាយកដ្ឋានត្រួតពិនិត្យ

# អារម្ភកថា



ការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យសេដ្ឋកិច្ចពិភពលោកទទួលរងផលប៉ះពាល់អវិជ្ជមាន ដែលបណ្តាលឱ្យកំណើនសេដ្ឋកិច្ចក្នុងបណ្តាប្រទេសធំៗជាច្រើនមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ និងប្រទេសមួយចំនួនទៀតមានកំណើនអវិជ្ជមាន។ អត្រាកំណើនសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២០ ត្រូវបានព្យាករថានឹងមានកម្រិត -៣,៥%។ ទន្ទឹមនេះ សេដ្ឋកិច្ចតំបន់អាស៊ី ក៏ត្រូវបានរំពឹងទុកថានឹងមានកំណើនអវិជ្ជមានប្រមាណ -៤,២%។ តាមរយៈការដាក់ចេញនូវវិធានការទប់ស្កាត់បានទាន់ពេលវេលារាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមាននៃការរីករាលដាលនៃជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ចកម្ពុជា ជាពិសេសវិស័យទេសចរណ៍ ការនាំចេញ និងសំណង់ ដែលរួមចំណែកប្រមាណ ៧០% នៅក្នុងសេដ្ឋកិច្ច។ ផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ-១៩ បានធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០ មានការថយចុះដល់ -៣,១%។ ទោះស្ថិតក្នុងបរិបទនៃវិបត្តិសុខភាពពិភពលោកក៏ដោយ វិស័យធនាគារកម្ពុជានៅបន្តរក្សាបានស្ថានភាពរឹងមាំ និងផ្តល់កិច្ចគាំពារដល់អតិថិជនដែលរងផលប៉ះពាល់គួរជាទីមោទនៈ។

ធនាគារជាតិនៃកម្ពុជា បានអនុវត្តជាដំណាក់កាលនូវការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត តាមរយៈការធ្វើកំណែទម្រង់រចនាសម្ព័ន្ធថ្មីរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ និងការដាក់ចេញបទប្បញ្ញត្តិជាបន្តបន្ទាប់ស្របតាមការអភិវឌ្ឍរបស់ទីផ្សារក្នុងនិងក្រៅប្រទេស។ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅតែជា ការងារអាទិភាពមួយនិងត្រូវបន្តអនុវត្តស្របតាមការវិវឌ្ឍយ៉ាងឆាប់រហ័សនិងភាពច្នៃប្រឌិតថ្មីៗនៃប្រព័ន្ធធនាគារ ដែលទាមទារឱ្យមានយន្តការតាមដាននិងត្រួតពិនិត្យជាប់ជាប្រចាំសំដៅធានាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន។ ជាក់ស្តែង ការដាក់ចេញវិធានការម៉ាក្រូប្រុងប្រយ័ត្ននានា ជាបន្តបន្ទាប់ និងទាន់ពេលវេលាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានមកលើប្រព័ន្ធធនាគារ ក៏ដូចជាបង្កើនភាពធន់នឹងវិបត្តិ និងកាត់បន្ថយ ឬចៀសវាងបាននូវហានិភ័យជាប្រព័ន្ធ។ សមិទ្ធផលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវបានទស្សនាវដ្តីអន្តរជាតិ The Banker និងមជ្ឈដ្ឋានអន្តរជាតិវាយតម្លៃខ្ពស់និងកោតសរសើរលើជោគជ័យក្នុងការគ្រប់គ្រងប្រព័ន្ធធនាគារបានល្អប្រសើរក្នុងដំណាក់កាលដែលកម្ពុជា ក៏ដូចជាពិភពលោកកំពុងជួបនឹងវិបត្តិជំងឺកូវីដ-១៩ ដែលចាប់ផ្តើមនៅឆ្នាំ២០២០កន្លងទៅ។

ឆ្លើយតបទៅនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុយ៉ាងឆាប់រហ័ស ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការជាផ្លូវការ "ប្រព័ន្ធបាគង" នៅខែតុលា ឆ្នាំ២០២០ ដែលប្រព័ន្ធនេះនឹងរួមចំណែកក្នុងការជំរុញការទូទាត់មិនប្រើសាច់ប្រាក់ បរិយាបន្នហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ប្រាក់រៀលក្នុងការទូទាត់សំដៅអភិវឌ្ឍសេដ្ឋកិច្ចឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកឌីជីថល

ស្របតាមបដិវត្តឧស្សាហកម្មទី៤ និងការអភិវឌ្ឍក្នុងតំបន់។ ការប្រើប្រាស់ និងការបញ្ចូលព័ត៌មានឥណទានរបស់ឯកត្តជន និងក្រុមហ៊ុនទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន កាន់តែមានចំនួនច្រើនឡើងដែលឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងហានិភ័យ ជាពិសេសការវិភាគគុណភាពឥណទានកាន់តែប្រសើរឡើង។ បន្ទាប់ពីយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ ២០១៩-២០២៥ ត្រូវបានអនុម័ត ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តតាមផែនការសកម្មភាពទាំង១១៥ និងគំនិតផ្តួចផ្តើមផ្សេងៗក្រោមកិច្ចសហការជាមួយភាគីជាដៃគូពាក់ព័ន្ធនានា។ ធនាគារជាតិនៃកម្ពុជា បានបន្តការផ្សព្វផ្សាយយុទ្ធនាការ បញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជួយដោះស្រាយចម្ងល់ និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" និងការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុ ទៅក្នុងកម្មវិធីសិក្សាទូទៅពីថ្នាក់ទី១-១២ និងក្រសួងកិច្ចការនារីក្នុងការរៀបចំសិក្ខាសាលា ស្តីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី"។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការ Good Return ដើម្បីបន្តកិច្ចសហប្រតិបត្តិការ ក៏ដូចជាការអនុវត្តគម្រោងយុទ្ធនាការប្រើប្រាស់លុយដោយឆ្លាតវៃ ដែលមានឈ្មោះថាយុទ្ធនាការ "តោះ! និយាយពីលុយៈ តក់ៗពេញបំពង់" បន្តពីយុទ្ធនាការ "តោះ! និយាយពីលុយ" ដែលមានស្រាប់។

ជាមួយគ្នាផងដែរ ធនាគារជាតិនៃកម្ពុជា នៅតែបន្តជំរុញ និងលើកទឹកចិត្តលើការកសាងសមត្ថភាពជំនាញរបស់មន្ត្រីត្រួតពិនិត្យ ទាំងផ្នែកទន់ (Soft skills) និងផ្នែករឹង (Hard skills) ជាប់ជាប្រចាំតាមរយៈការសិក្សាតាមប្រព័ន្ធអនឡាញ ជាមួយដៃគូអភិវឌ្ឍន៍នានា ទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគីក្នុងទិសដៅបន្តលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងារ។

ធនាគារជាតិនៃកម្ពុជា បន្តរក្សាស្ថិរភាពថ្លៃស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ និងបន្តចូលរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល តាមរយៈការលើកកម្ពស់ជំនឿទុកចិត្តរបស់សាធារណជន ក៏ដូចជាបន្តរក្សាឱ្យបាននូវប្រសិទ្ធភាព ភាពរឹងមាំ ការប្រកួតប្រជែង និងសមាហរណកម្មខ្ពស់ ក្នុងប្រព័ន្ធធនាគារនៅកម្ពុជា។ ធនាគារជាតិនៃកម្ពុជា នឹងបន្តលើកកម្ពស់ការត្រួតពិនិត្យ កិច្ចគាំពារអតិថិជន ការប្រើប្រាស់រូបិយវត្ថុជាតិ និងបរិយាបន្នហិរញ្ញវត្ថុផងដែរ។ ខ្ញុំសង្ឃឹមថា របាយការណ៍សនេះនឹងអាចប្រើប្រាស់ជាឯកសារសម្រាប់បង្កើនការយល់ដឹងបន្ថែមអំពីវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

ថ្ងៃពុធ ៧រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១

**ជា ចាន់តូ**

**ទេសាភិបាល**

**ធនាគារជាតិនៃកម្ពុជា**

# មាតិកា

**អារម្ភកថា** ........ i

**បញ្ជីរូបភាព និងតារាង** ........ v

**១. ការអភិវឌ្ឍសំខាន់ៗនៃប្រព័ន្ធធនាគារ** ........ **១**

១.១. ទិដ្ឋភាពទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១

១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ ........ ១

១.២.១. ប្រតិបត្តិការនៃវិស័យធនាគារ ........ ៣

១.២.២. ប្រតិបត្តិការនៃវិស័យមីក្រូហិរញ្ញវត្ថុ ........ ៦

១.២.៣. ប្រតិបត្តិការនៃវិស័យភតិសន្យាហិរញ្ញវត្ថុ ........ ១០

១.២.៤. ប្រតិបត្តិការនៃគ្រឹះស្ថានឥណទានជនបទ ........ ១០

១.២.៥. ប្រតិបត្តិការនៃអាជីវកម្មប្តូរប្រាក់ ........ ១១

១.២.៦. ប្រតិបត្តិការនៃគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ........ ១២

១.២.៧. ប្រតិបត្តិការទីផ្សារអន្តរធនាគារ ........ ១៣

**២. ការវិវឌ្ឍក្របខណ្ឌនៃការត្រួតពិនិត្យនិងបទប្បញ្ញត្តិ** ........ **១៤**

២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ ........ ១៤

២.១.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិក្នុងឆ្នាំ២០២០ ........ ១៤

២.១.២ បទប្បញ្ញត្តិឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ........ ១៤

២.២. សកម្មភាពនៃការត្រួតពិនិត្យ ........ ១៦

២.៣. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ ........ ១៧

**៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់** ........ **១៩**

៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ........ ១៩

៣.១.១. ស្តង់ដាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ........ ១៩

៣.១.២. ការចែករំលែកព័ត៌មានឥណទាន ........ ២១

៣.២. ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ........ ២៣

៣.២.១. ការអប់រំផ្នែកហិរញ្ញវត្ថុ ........................................................................ ២៤
៣.២.១.១. សិក្ខាសាលាផ្សព្វផ្សាយអំពីវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា............ ២៤
៣.២.១.២. កិច្ចសហការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ........................ ២៥
៣.២.១.៣. យុទ្ធនាការ "តោះ! និយាយពីលុយ"............................................ ២៦
៣.២.២ កិច្ចការពារអតិថិជន និងយន្តការគ្រប់គ្រងនិងដោះស្រាយបណ្តឹង ...................... ២៦
**៤. ការកសាងសមត្ថភាពត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ........................ ២៧**
៤.១. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ ........................................................................ ២៧
៤.២. កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ..................................................................... ២៧
៤.២.១. កិច្ចសហប្រតិបត្តិការការងារបរិយាបន្នហិរញ្ញវត្ថុ ............................................. ២៧
៤.២.២. កិច្ចសហប្រតិបត្តិការការងារជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ................ ២៩
៤.២.៣. កិច្ចសហប្រតិបត្តិការការងារជាមួយអាជ្ញាធរពាក់ព័ន្ធ ........................................៣០
**បញ្ជីឧបសម្ព័ន្ធ .................................................................................................. ៣១**

# បញ្ជីរូបភាព និងតារាង

## រូបភាព


រូបភាព១ ៖ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ........................................ ២
រូបភាព២ ៖ ចំនួនប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ............. ២
រូបភាព៣ ៖ ធនាគារ-ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច............................ ៤
រូបភាព៤ ៖ ធនាគារ-ឥណទាន និងប្រាក់បញ្ញើអតិថិជន................................................ ៤
រូបភាព៥ ៖ ធនាគារ-ចំនួនគណនីឥណទាន និងប្រាក់បញ្ញើអតិថិជន ............................ ៥
រូបភាព៦ ៖ ធនាគារ-អនុបាតឥណទានមិនដំណើរការ ................................................. ៦
រូបភាព៧ ៖ ធនាគារ-អត្រាការប្រាក់លើប្រាក់បញ្ញើ និងឥណទាន (ប្រាក់រៀល និងដុល្លារអាមេរិក) ................................................................................................................ ៦
រូបភាព៨ ៖ មីក្រូហិរញ្ញវត្ថុ-កំណើនទ្រព្យសកម្ម............................................................ ៧
រូបភាព៩ ៖ មីក្រូហិរញ្ញវត្ថុ-ឥណទាន និងប្រាក់បញ្ញើ .................................................... ៨
រូបភាព១០ ៖ មីក្រូហិរញ្ញវត្ថុ-ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច.................... ៨
រូបភាព១១ ៖ មីក្រូហិរញ្ញវត្ថុ-អត្រាការប្រាក់លើប្រាក់បញ្ញើ និងឥណទាន (ប្រាក់រៀល និងដុល្លារអាមេរិក) ........................................................................................ ៩
រូបភាព១២ ៖ មីក្រូហិរញ្ញវត្ថុ-អនុបាតឥណទានមិនដំណើរការ និងអនុបាតប្រាក់ចំណេញ .. ៩
រូបភាព១៣ ៖ ប្រភេទអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់..................១១
រូបភាព១៤ ៖ ចំនួនលិខិតអនុញ្ញាតប្តូរប្រាក់នៅតាមខេត្ត............................................ ១២
រូបភាព១៥ ៖ ចំណែកទីផ្សារឥណទានទៅវិស័យអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ...........................................................................................................១៨
រូបភាព១៦ ៖ លំហូរចូលនៃការវិនិយោគផ្ទាល់បរទេសក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា .១៨
រូបភាព១៧ ៖ ឥណទានទៅវិស័យអចលនទ្រព្យ..........................................................១៩
រូបភាព១៨ ៖ គ្រឹះស្ថានជាសមាជិករបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី .... ២១
រូបភាព១៩ ៖ សំពៀតឥណទាននិងចំនួនគណនីបែងចែកតាមប្រភេទ .......................... ២២
រូបភាព២០ ៖ សំពៀតឥណទានសរុបបែងចែកតាមប្រភេទគ្រឹះស្ថានជាសមាជិក............ ២២
រូបភាព២១ ៖ ការពិនិត្យរបាយការណ៍ឥណទានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន..២៣


## តារាង


តារាង១ ៖ ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារតាមប្រភេទភាគទុនិក ............................ ១
តារាង២ ៖ ការវិវឌ្ឍក្នុងវិស័យធនាគារ.......................................................................៣
តារាង៣ ៖ វិស័យភតិសន្យាហិរញ្ញវត្ថុ.......................................................................១០
តារាង៤ ៖ ការវិនិយោគក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា ..........................................១៨


## ប្រអប់


ប្រអប់១ ៖ ផលប៉ះពាល់ដោយសារកូវីដ-១៩មកលើប្រព័ន្ធធនាគារនៅកម្ពុជា និងយន្តការឆ្លើយតប ព្រមទាំងកាលានុវត្តភាព ........................................................ ២០

# ទិន្នន័យទាំងអស់មិនទាន់ត្រូវបានធ្វើសវនកម្ម
# និងត្រូវបានរាយការណ៍ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ១. ការអភិវឌ្ឍសំខាន់ៗនៃប្រព័ន្ធធនាគារ

### ១.១. ចិដ្ឋភាពទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាស្ថិរភាពប្រព័ន្ធធនាគារកម្ពុជា។ តាមរយៈការដាក់ចេញនូវវិធានការគាំពារចាំបាច់នានារបស់ធនាគារជាតិនៃកម្ពុជា ប្រព័ន្ធធនាគារបន្តរក្សាបាននូវភាពធន់ និងជំនឿទុកចិត្តពីសាធារណជន។ ប្រព័ន្ធធនាគារ រួមមាន ធនាគារពាណិជ្ជ ៥១ ធនាគារឯកទេស ១២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៥ គ្រឹះស្ថានឥណទានជនបទ ២៤៥ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ២៤ ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៦ និងអាជីវកម្មប្តូរប្រាក់ ២.៨៨៩។

តារាង១៖ ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារតាមប្រភេទភាគទុនិក

| ចំណែកទីផ្សារ | ទ្រព្យសកម្ម | | ឥណទាន | | ប្រាក់បញ្ញើ | | ដើមទុន | |
|---|---|---|---|---|---|---|---|---|
| | ធ្នូ-១៩ | ធ្នូ-២០ | ធ្នូ-១៩ | ធ្នូ-២០ | ធ្នូ-១៩ | ធ្នូ-២០ | ធ្នូ-១៩ | ធ្នូ-២០ |
| **ធនាគារពាណិជ្ជ** | | | | | | | | |
| ធនាគារបរទេស | ៥១,៦% | ៦២,៣% | ៤៨,៥% | ៦១,៣% | ៤៧,៤% | ៥៧,៦% | ៥០,១% | ៦៥,៣% |
| ធនាគារក្នុងស្រុក | ៤៦,៣% | ៣៦,៦% | ៤៨,៨% | ៣៧,៤% | ៥២,៦% | ៤២,៤% | ៤២,០% | ៣០,៥% |
| **ធនាគារឯកទេស** | | | | | | | | |
| ធនាគារបរទេស | ១,៣% | ០,៨% | ១,៨% | ១,០% | ០,០% | ០,០% | ៤,២% | ២,៣% |
| ធនាគារក្នុងស្រុក | ០,៨% | ០,៣% | ០,៩% | ០,៣% | ០,០% | ០,០% | ៣,៧% | ១,៩% |
| **សរុប** | | | | | | | | |
| ធនាគារបរទេស | ៥២,៩% | ៦៣,១% | ៥០,៣% | ៦២,៣% | ៤៧,៤% | ៥៧,៦% | ៥៤,៣% | ៦៧,៦% |
| ធនាគារក្នុងស្រុក | ៤៧,១% | ៣៦,៩% | ៤៩,៧% | ៣៧,៧% | ៥២,៦% | ៤២,៤% | ៤៥,៧% | ៣២,៤% |
| **សរុប** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ

ប្រព័ន្ធធនាគារ បានបន្តវឌ្ឍនភាព និងរួមចំណែកគាំទ្រយ៉ាងសកម្មដល់សកម្មភាពនានានៃសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន ១៥,២% ដល់ ២៣៩,៤ ទ្រីលានរៀល (៥៩,២ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទានអតិថិជនបានកើនឡើង ១៦,៩% ដល់ ១៥៣,០ ទ្រីលានរៀល (៣៧,៨ ប៊ីលានដុល្លារអាមេរិក)។ ទន្ទឹមនេះ ប្រាក់បញ្ញើអតិថិជនមានកំណើន ១៤,៩% ដល់ ១៣៥,៧ ទ្រីលានរៀល (៣៣,៦ ប៊ីលានដុល្លារអាមេរិក) និងដើមទុនមានកំណើន ១៧,២% ដល់ ៤៦,៨ ទ្រីលានរៀល (១១,៦ ប៊ីលានដុល្លារអាមេរិក)។

រូបភាព១៖ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

រូបភាព២៖ ចំនួនប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានបន្តផ្តល់សេវាជូនអតិថិជនកាន់តែច្រើនឡើង ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនចំនួនគណនីប្រាក់បញ្ញើអតិថិជនដល់ ៨,៩ លានគណនី និងគណនីឥណទានអតិថិជនកើនដល់ ៣,២ លានគណនី។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏បានពង្រីកបណ្តាញប្រតិបត្តិការហិរញ្ញវត្ថុរហូតដល់ចំនួន ២.៥៤២ ទីតាំង និងមានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន ៣.១៧៧ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយ។ ដើម្បីរួមចំណែកអនុវត្តតាមវិធានការរបស់ធនាគារជាតិនៃកម្ពុជាក្នុងការជួយសម្រាលបន្ទុកប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានរៀបចំ

ឥណទានឡើងវិញចំនួន ២៩២.៧៩០ គណនី ស្មើនឹង ១៦.៣៩៥,៩ ប៊ីលានរៀល (៤,០៩៣.២ លានដុល្លារអាមេរិក)។

ស្របគ្នានឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានធ្វើទំនើបកម្មកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ ស្របពេលដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏បានធ្វើ ពិពិធកម្មសេវាហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីសម្រួលដល់ការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់អតិថិជនតាមរយៈបណ្ណឥណពន្ធនិងបណ្ណឥណទាន ការផ្តល់សេវាផ្ទេរប្រាក់ និងការទូទាត់សងប្រាក់តាមអេឡិចត្រូនិក ជាដើម។

### ១.២.១. ប្រតិបត្តិការនៃវិស័យធនាគារ

ទោះបីជាស្ថិតក្នុងបរិការណ៍នៃវិបត្តិសុខភាពពិភពលោក ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារនៅតែបន្តកើនឡើងក្នុងកម្រិតល្អប្រសើរ ១៩,៧% ដល់ ២០៣,៥ ទ្រីលានរៀល (៥០,៣ ប៊ីលានដុល្លារអាមេរិក)។ ប្រភពសំខាន់ៗនៃមូលនិធិរបស់វិស័យធនាគារបានមកពីប្រាក់បញ្ញើអតិថិជន ១២១,៣ ទ្រីលានរៀល (៣០,០ ប៊ីលានដុល្លារអាមេរិក) មូលនិធិភាគទុនិក ៣៨,៦ ទ្រីលានរៀល (៩,៥ ប៊ីលានដុល្លារអាមេរិក) និងមូលនិធិកម្ចី ៥,៩ ទ្រីលានរៀល (១,៥ ប៊ីលានដុល្លារអាមេរិក)។

តារាង២ ៖ ការវិវឌ្ឍក្នុងវិស័យធនាគារ

| ការវិវឌ្ឍក្នុងវិស័យធនាគារ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| កំណើនទ្រព្យសកម្ម | ២០,៩% | ២០,១% | ២១,៤% | ២១,៥% | ១៩,៧% |
| កំណើនឥណទានអតិថិជន | ២០,៥% | ១៧,២% | ២៤,៣% | ២៣,៩% | ១៦,១% |
| កំណើនប្រាក់បញ្ញើ | ២១,៨% | ២៥,១% | ២៧,៩% | ១៥,១% | ១៩,៥% |
| ទ្រព្យសកម្មធៀបផ.ស.ស | ១១៨,២% | ១៩២,០% | ១៩៣,៦% | ១៥៥,១% | ១៨៦,១% |
| ឥណទានធៀបផ.ស.ស | ៦៨,៨% | ៨០,៧% | ៨៣,៥% | ៩២,០% | ១១៩,៨% |
| ប្រាក់បញ្ញើធៀបផ.ស.ស | ៦៨,៤% | ៨៥,៦% | ៩១,១% | ៩៣,៣% | ១១០,៩% |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ឥណទានដុលបានកើនឡើងដល់ ១៣១,២ ទ្រីលានរៀល ដែលក្នុងនោះឥណទានអតិថិជនបានកើនឡើង ១៦,១% ដល់ ១២៥,៥ ទ្រីលានរៀល (៣១,០ ប៊ីលានដុល្លារអាមេរិក)។ ឥណទានដែលជាប្រភពទុនយ៉ាងសំខាន់ក្នុងការគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច ត្រូវបានបែងចែកទៅតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច រួមមាន ការជួញដូររាយ ១៥,៤% ការជួញដូរដុំ ៩,៧% ការទិញ

ផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ១៣,១% សំណង់ ៩,៧% ការឱ្យខ្ចីជាបុគ្គល ៩,៨% ការជួញដូរអចលនទ្រព្យ ៨,៣% កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៧,៥% សេវាកម្មមិនមែនហិរញ្ញវត្ថុ ៥,២% កម្មន្តសាលកម្ម ៤,០% សណ្ឋាគារនិងភោជនីយដ្ឋាន ៣,៩% និងវិស័យផ្សេងៗ ១៣,៤%។

*រូបភាព៣៖ ធនាគារ-ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច*




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទំហំនៃប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារបានកើនឡើង ១៤,៥% ហើយគណនីប្រាក់បញ្ញើបានកើនដល់ ៦,៣ លានគណនី រួមមាន ឯកត្តជន ៥៥,៥% សហគ្រាសអាជីវកម្ម ២២,៣% គ្រឹះស្ថានធនាគារក្នុងស្រុកនិងក្រៅប្រទេស ១១,៦% អនិវាសជន ៦,៤% និងគ្រឹះស្ថានផ្សេងៗ ៤,២%។ កំណើនប្រាក់បញ្ញើពីសាធារណជនបានឆ្លុះបញ្ចាំងពីការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើរាជរដ្ឋាភិបាល និងប្រព័ន្ធធនាគារកម្ពុជា តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការរក្សាស្ថិរភាពនយោបាយ និងធនាគារជាតិនៃកម្ពុជាក្នុងការរក្សាស្ថិរភាពថ្លៃនិងចូលរួមជាមួយស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។

*រូបភាព៤៖ ធនាគារ-ឥណទាន និងប្រាក់បញ្ញើអតិថិជន*




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់វិស័យធនាគារបន្តអភិវឌ្ឍជាលំដាប់ តាមរយៈការពង្រីកបណ្តាញប្រតិបត្តិការថ្មីបន្ថែម ដោយការបើកសាខាចំនួន ៣៩១ សាខា និងការដាក់ឱ្យប្រើប្រាស់នូវម៉ាស៊ីន ATM ចំនួន៥១៩ និងម៉ាស៊ីន POS សរុបចំនួន ២២.៩២៨ ម៉ាស៊ីន។ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងភាពល្អប្រសើរនៃកម្រិតជីវភាពរស់នៅរបស់ប្រជាជន ការប្រើប្រាស់បណ្ណជំនួសសាច់ប្រាក់មានការកើនឡើងគួរឱ្យកត់សម្គាល់ដោយបណ្ណឥណទាន និងបណ្ណឥណពន្ធបានកើនដល់ ១៣១.០៧៧ បណ្ណ និង ២.៧៥៩.៥៥៣ បណ្ណ រៀងគ្នា។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារភាគច្រើនបាននិងកំពុងអភិវឌ្ឍសេវាហិរញ្ញវត្ថុឌីជីថល ដូចជា ការប្រើប្រាស់សេវាធនាគារតាមរយៈប្រព័ន្ធអ៊ីនធឺណិត និងទូរស័ព្ទដៃជាដើម ដែលឆ្លើយតបនឹងការកើនឡើងនៃតម្រូវការរបស់អតិថិជន។

**រូបភាព៥ ៖ ធនាគារ-ចំនួនគណនីឥណទាន និងប្រាក់បញ្ញើអតិថិជន**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ជារួម គ្រឹះស្ថានធនាគារមានសុខភាពល្អប្រសើរ និងអាចធន់នឹងហានិភ័យនានា ដែលឆ្លុះបញ្ចាំងតាមរយៈអភិបាលកិច្ចល្អ ការត្រួតពិនិត្យផ្ទៃក្នុងម៉ឹងម៉ាត់ និងភាពរឹងមាំនៃគុណភាពទ្រព្យសកម្មក៏ដូចជា ការអនុលោមតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន មានដូចជា អនុបាតសាធនភាព និងអនុបាតសន្ទនីយភាពដែលរក្សាបានក្នុងកម្រិត ២៣,២% និង ១៦១,២% រៀងគ្នា។ លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារនៅបន្តមានភាពល្អប្រសើរ ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) មាន ១,៧% និងអនុបាតប្រាក់ចំណេញធៀបនឹងដើមទុន (ROE) មាន ៨,៩%។ ស្របពេលដែលសេដ្ឋកិច្ចពិភពលោក ក៏ដូចជាប្រទេសកម្ពុជាកំពុងប្រឈមនឹងវិបត្តិសុខភាពពិភពលោក អនុបាតឥណទានមិនដំណើរការបានកើនឡើងពី ២% ចំនួនដល់ ២,១%។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការសំខាន់ៗមួយចំនួនដូចជា ឥណទានរៀបចំឡើងវិញ និងការលើកទឹកចិត្តឱ្យមានការអនុគ្រោះ និង/ឬ ការលើកលែងចំពោះការដាក់ពិន័យផ្សេងៗលើឥណទានជាដើម ក្នុងន័យរួមចំណែកកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ មកលើអតិថិជនដែលកំពុងជួបប្រទះបញ្ហាហិរញ្ញវត្ថុ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

រូបភាព៦៖ ធនាគារ-អនុបាតឥណទានមិនដំណើរការ




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

អត្រាការប្រាក់លើប្រាក់បញ្ញើនិងឥណទានអតិថិជន ដោយគណនាតាមវិធីសាស្ត្រអត្រាការប្រាក់ថ្លឹងជាមធ្យម (Weighted Average Interest Rate) បានបង្ហាញថា អត្រាការប្រាក់លើប្រាក់បញ្ញើជារៀលនិងដុល្លារអាមេរិកមានការថយចុះបន្តិចបើធៀបនឹងឆ្នាំ២០១៩ ក្នុងកម្រិត ៥,៦% និង ៤,៣% រៀងគ្នា។ ដូចនេះ អត្រាការប្រាក់លើឥណទានជារៀល បានបន្តថយចុះពីអត្រា ១០,៥% នៅឆ្នាំ២០១៩ មកត្រឹម ១០,៣% នៅឆ្នាំ២០២០ ប៉ុន្តែអត្រាការប្រាក់លើឥណទានជាដុល្លារអាមេរិកបានកើនឡើងពី ៨,៨% នៅឆ្នាំ២០១៩ ដល់ ៩,១% នៅឆ្នាំ២០២០។

រូបភាព៧៖ ធនាគារ-អត្រាការប្រាក់លើប្រាក់បញ្ញើ និងឥណទាន (ប្រាក់រៀល និងដុល្លារអាមរិក)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ១.២.២. ប្រតិបត្តិការនៃវិស័យមីក្រូហិរញ្ញវត្ថុ

ក្នុងស្ថានភាពដែលកម្ពុជារងផលប៉ះពាល់ពីវិបត្តិសុខភាពពិភពលោកក៏ដោយ វិស័យមីក្រូហិរញ្ញវត្ថុនៅតែបន្តការរីកចម្រើនដែលឆ្លុះបញ្ចាំងតាមរយៈជំនឿទុកចិត្តរបស់សាធារណជន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពីប្រជាជននៅតាមជនបទនៅតែបន្តកើនឡើង។ ទំហំទ្រព្យសកម្ម

របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង ១៨,៨% ដល់ ៣៤,៣ ទ្រីលានរៀល (៨,៥ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទាន កើនឡើង ១៧,៥% ដល់ ២៧,៥ ទ្រីលានរៀល (៦,៨ ប៊ីលានដុល្លារអាមេរិក) ដែលគាំទ្រដោយ កំណើនមូលនិធិភាគទុនិក ៣៤,១% ដល់ ៧,៧ ទ្រីលានរៀល (១,៩ ប៊ីលានដុល្លារអាមេរិក) និងកំណើនប្រាក់បញ្ញើ ១៨,៨% ដល់ ១៤,៥ ទ្រីលានរៀល (៣,៦ ប៊ីលានដុល្លារអាមេរិក)។ ការធ្លាក់ចុះនៃកំណើនទ្រព្យសកម្ម ឥណទាន និងប្រាក់បញ្ញើរបស់វិស័យមីក្រូហិរញ្ញវត្ថុ គឺបណ្តាលមកពីការកម្លាយខ្លួនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅជាធនាគារពាណិជ្ជ និងការរួមបញ្ចូលគ្នារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាមួយធនាគារពាណិជ្ជ។

រូបភាព៨៖ មីក្រូហិរញ្ញវត្ថុ-កំណើនទ្រព្យសកម្ម




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

កំណើនឥណទានរបស់វិស័យមីក្រូហិរញ្ញវត្ថុ បន្តគាំទ្រដល់សកម្មភាពសេដ្ឋកិច្ចធុនតូច និងមធ្យមនៅមូលដ្ឋាន ដូចជា ជំនួញលក្ខណៈគ្រួសារ ៣១,៣% ពាណិជ្ជកម្មនិងជំនួញ ២០,៩% កសិកម្ម ១៩,៣% សេវាកម្ម ១៥,៩% ដឹកជញ្ជូន ៥,៩% សំណង់ ៣,៨% និងវិស័យផ្សេងៗ ២,៩%។ ឆ្លើយតបនឹងការជំរុញបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា វិស័យមីក្រូហិរញ្ញវត្ថុបានចូលរួមស្រូបទាញអតិថិជនឱ្យចេះប្រើប្រាស់សេវាហិរញ្ញវត្ថុ ដូចជា ការដាក់ប្រាក់បញ្ញើ និងការខ្ចីឥណទានចំនួន ២,៧ លានគណនី និង ១,៩ លានគណនី រៀងគ្នា។

**រូបភាព៩៖ មីក្រូហិរញ្ញវត្ថុ-ឥណទាន និងប្រាក់បញ្ញើ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**រូបភាព១០៖ មីក្រូហិរញ្ញវត្ថុ-ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

អត្រាការប្រាក់លើប្រាក់បញ្ញើជារៀល និងដុល្លារអាមេរិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានកម្រិត ៧,៥% និង ៧,៩% រៀងគ្នា។ បន្ទាប់ពីការដាក់ចេញនូវពិដាន អត្រាការប្រាក់លើឥណទាន ១៨% កន្លងមក អត្រាការប្រាក់លើឥណទានប្រចាំឆ្នាំមានកម្រិត ១៥,៩% សម្រាប់ឥណទានជាប្រាក់រៀល និង ១៥,២% ជាដុល្លារអាមេរិក ដែលថយចុះបន្តិចបើធៀបនឹងដំណាច់ឆ្នាំ២០១៩។

**រូបភាព១១៖ មីក្រូហិរញ្ញវត្ថុ-អត្រាការប្រាក់លើប្រាក់បញ្ញើ និងឥណទាន (ប្រាក់រៀល និងដុល្លារអាមេរិក)**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅបន្តអនុវត្តបានតាម បទប្បញ្ញត្តិប្រុងប្រយ័ត្ននានារបស់ធនាគារជាតិនៃកម្ពុជា ដូចជា អនុបាតសាធនភាព ២២,៩% និងអនុបាតសន្ទនីយភាព ២៩០,៩% ជាដើម។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅបន្តរក្សាបាននូវប្រាក់ចំណេញរបស់ខ្លួនតាមរយៈអនុបាត ដូចជា ROA ២,៨% និង ROE ១២,៩%។ ដោយឡែក អនុបាតឥណទានមិនដំណើរការមានការកើនឡើងដល់ ១,៨% ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងការបាត់បង់ចំណូលចម្បងរបស់អ្នកខ្ចីប្រាក់។ ការទទួលបាននូវសេវាហិរញ្ញវត្ថុចម្បងៗក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅតាមជនបទ នៅតែបន្តកើនឡើង ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានពង្រីកសក្តានុពលនិងវិសាលភាពនៃសេវាកម្មរបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការ។ ជាក់ស្តែងបណ្តាញប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានគ្របដណ្តប់ទូទាំង ២៥ ខេត្ត-ក្រុង មាន ១.១៧១ ការិយាល័យ។ ទន្ទឹមនេះ សេវាហិរញ្ញវត្ថុត្រូវបានបន្តធ្វើទំនើបកម្ម និងពិពិធកម្មជាបន្តបន្ទាប់។

**រូបភាព១២៖ មីក្រូហិរញ្ញវត្ថុ-អនុបាតឥណទានមិនដំណើរការ និងអនុបាតប្រាក់ចំណេញ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ការណ៍នេះបង្ហាញថា វិស័យមីក្រូហិរញ្ញវត្ថុបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ជីវភាពរស់នៅតាមមូលដ្ឋាន តាមរយៈការផ្ដល់សេវាឥណទានសម្រាប់ការប្រើប្រាស់ និងការប្រកបអាជីវកម្មខ្នាតតូចនិងមធ្យម។

### ១.២.៣. ប្រតិបត្តិការនៃវិស័យភតិសន្យាហិរញ្ញវត្ថុ

វិស័យភតិសន្យាហិរញ្ញវត្ថុ បានចូលរួមចំណែកផ្ដល់សេវាហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជាប្រកបដោយបរិយាបន្ន តាមរយៈការបន្តពង្រីកសេវាភតិសន្យាហិរញ្ញវត្ថុជូនអតិថិជនទៅលើចលនវត្ថុដូចជា ម៉ូតូ រថយន្ត គ្រឿងយន្តកសិកម្ម គ្រឿងចក្រ គ្រឿងអេឡិចត្រូនិក គ្រឿងសង្ហារឹម និងចលនទ្រព្យផ្សេងៗទៀត។ ទ្រព្យសកម្មសរុបរបស់វិស័យភតិសន្យាហិរញ្ញវត្ថុបានកើនឡើងដល់ ១.៦ ទ្រីលានរៀល (៣៩៩,៥ លានដុល្លារអាមេរិក) ដែលក្នុងនោះភតិសន្យាហិរញ្ញវត្ថុសរុបបានកើនឡើងដល់ ១.៣ ទ្រីលានរៀល (៣៣៣,៩ លានដុល្លារអាមេរិក) ដែលត្រូវបានបែងចែកទៅក្រុមគ្រួសារ ២២,៩% សេវាកម្ម ១៨,៣% ការដឹកជញ្ជូន ១៥,៨% កសិកម្ម ១៤,៨% សំណង់ ៦,៧% ពាណិជ្ជកម្ម ៤,៧% និងផ្សេងៗ ១៦,៨%។ ទន្ទឹមនេះ ឥណទានមិនដំណើរការក្នុងវិស័យនេះមានកម្រិត ៤,៦%។

តារាង៣៖ វិស័យភតិសន្យាហិរញ្ញវត្ថុ

គិតជាប៊ីលានរៀល

| ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| ចំនួនទ្រព្យសកម្មសរុប | ៦២២,៨ | ៧០៧,៩ | ៩៥១,៦ | ១.៣៥៩,១ | ១.៦១៦,១ |
| ចំនួនភតិសន្យាហិរញ្ញវត្ថុសរុប | ៤៨៥,០ | ៥២៥,៣ | ៧១៣,៨ | ១.១៦៩,៦ | ១.៣៥០,៥ |
| ឥណទានមិនដំណើរការ | ៥,៩% | ៥,៣% | ៨,៤% | ៣,៣% | ៤,៦% |
| មូលនិធិផ្ទាល់សុទ្ធ | ១១៣,៣ | ១៧៣,៥ | ៣៣៥,២ | ៤២២,៣ | ៥២៤,៨ |
| ចំនួនអតិថិជន | ៦១.៣៧២ | ៦៤.២៥២ | ៧២.៩២១ | ៩២.២៨៩ | ១០១.០១៨ |
| ចំនួនបុគ្គលិក | ១.២៤៥ | ១.២៦៦ | ១.៣៦១ | ១.៤៦០ | ១.៧៦០ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ១.២.៤. ប្រតិបត្តិការនៃគ្រឹះស្ថានឥណទានជនបទ

គ្រឹះស្ថានឥណទានជនបទ បានចូលរួមយ៉ាងសកម្មក្នុងការផ្ដល់សេវាឥណទានខ្នាតតូចបំផុតនិងតូចជូនដល់ប្រជាជននៅតាមទីជនបទដាច់ស្រយាល។ ការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដែលសមស្របនិងមានតម្លៃសមរម្យ បានរួមចំណែកលើកកម្ពស់ជីវភាពប្រជាជន ដែលមានចំណូលទាបបានប្រសើរជាង។ គិតត្រឹមដំណាច់ឆ្នាំ២០២០ គ្រឹះស្ថានឥណទានជនបទ មានចំនួន ២៤៥ ដោយមានទំហំទ្រព្យសកម្មសរុប ៣៤១,៩ ប៊ីលានរៀល (៨៤,៥ លានដុល្លារ អាមេរិក) ដែលក្នុងនោះឥណទានសរុបមាន ២៨៥,៣ ប៊ីលានរៀល (៧០,៥ លានដុល្លារអាមេរិក) ដែលបានផ្ដល់ដល់អតិថិជន សរុបដែលមាន ៩៣.៩៧២ គណនី។ ឥណទានត្រូវបានបែងចែក ទៅវិស័យនានា

ដូចជា កសិកម្ម ៣៣,៩% ពាណិជ្ជកម្ម ២០,២% សំណង់ ១៨,៦% ក្រុមគ្រួសារ ១១,៨% ដឹកជញ្ជូន ៨,២% សេវាកម្ម ១,៥% និងផ្សេងៗ ១០,២%។ អនុបាតឥណទានមិនដំណើរការមានកម្រិតខ្ពស់ដល់ ១៧,០% និងឥណទានភាគច្រើនមិនមានវត្ថុបញ្ចាំ។

### ១.២.៥. ប្រតិបត្តិការនៃអាជីវកម្មប្តូរប្រាក់

ធនាគារជាតិនៃកម្ពុជា បានបន្តលើកទឹកចិត្តឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងប្រកបអាជីវកម្មប្តូរប្រាក់ស្របច្បាប់ ឬកំពុងប្រកបអាជីវកម្មប្តូរប្រាក់ដោយមិនមានច្បាប់អនុញ្ញាត ធ្វើការស្នើសុំ អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតត្រឹមត្រូវ មុននឹងដំណើរការអាជីវកម្មប្តូរប្រាក់។ ជាមួយគ្នានេះ អាជីវករប្តូរប្រាក់ ត្រូវគោរពតាមស្មារតីនៃប្រកាសស្តីពី "ការផ្តល់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតសម្រាប់អាជីវកម្មប្តូរប្រាក់" និងបទប្បញ្ញត្តិជាធរមាន។ ជាក់ស្តែង អាជីវកម្មប្តូរប្រាក់សរុបទូទាំងប្រទេសមានចំនួន ២.៨៨២ ក្នុងនោះមានអាជ្ញាបណ្ណចំពោះក្រុមហ៊ុននិងអាជីវករប្តូរប្រាក់ ១៩ គ្រឹះស្ថានធនាគារ ៤ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣ ព្រមទាំងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ ២.៨៥៦។

រូបភាព១៣៖ អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

រូបភាព១៨៖ ចំនួនលិខិតអនុញ្ញាតប្តូរប្រាក់នៅតាមខេត្ត




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ១.២.៦. ប្រតិបត្តិការនៃគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ប្រព័ន្ធទូទាត់ត្រូវបានធ្វើទំនើបកម្មជាបន្តបន្ទាប់ និងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធធនាគារ និងសេដ្ឋកិច្ចតាមរយៈការផ្តល់មធ្យោបាយទូទាត់ងាយស្រួល សុវត្ថិភាព រហ័ស និងកម្រៃសមរម្យក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ ប្រព័ន្ធទូទាត់ បានរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពដំណើរការផ្គត់ផ្គង់រូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈការចូលរួមកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ ទាំងប្រាក់រៀលនិងដុល្លារអាមេរិកដែលមានចំណាយកម្រៃប្រតិបត្តិការខ្ពស់ រួមទាំងជំរុញបរិយាបន្នហិរញ្ញវត្ថុ ដូចជា ការផ្តល់សេវានិងឧបករណ៍ថ្មីៗដែលមានកម្រៃទាប និងបង្កើនលទ្ធភាពពង្រីកបណ្តាញផ្តល់សេវាទូទាត់ឲ្យកាន់តែទូលំទូលាយ ដែលអនុញ្ញាតឲ្យប្រជាជននៅតាមទីជនបទចូលរួមប្រើប្រាស់សេវាទូទាត់ផ្លូវការកាន់តែប្រសើរជាងមុន។

ឆ្លើយតបទៅនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា បានផ្តួចផ្តើមគំនិតក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់នៅក្នុងប្រទេស តាមរយៈការអភិវឌ្ឍន៍ប្រព័ន្ធបាគង និងបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៅខែតុលា ឆ្នាំ២០២០។ ប្រព័ន្ធនេះនឹងរួមចំណែកក្នុងការជំរុញការទូទាត់មិនប្រើសាច់ប្រាក់ និងបរិយាបន្នហិរញ្ញវត្ថុសំដៅអភិវឌ្ឍសេដ្ឋកិច្ចឆ្ពោះទៅរកសេដ្ឋកិច្ចផ្នែកឌីជីថលស្របតាមបដិវត្តឧស្សាហកម្មទី៤ និងការអភិវឌ្ឍក្នុងតំបន់។ ប្រព័ន្ធ "បាគង" ត្រូវបានប្រើប្រាស់ដោយបច្ចេកវិទ្យា Blockchain និងគោរពតាមគោលការណ៍ដែលអាចកំណត់សម្គាល់អត្តសញ្ញាណរបស់អតិថិជនបានយ៉ាងច្បាស់លាស់ និងត្រឹមត្រូវ។ បច្ចេកវិទ្យានេះមានសមត្ថភាពខ្ពស់ក្នុងការការពារពីការលួចវាយប្រហារពីជនអនាមិកចូលទៅក្នុងប្រព័ន្ធ ក៏ដូចជាតាមដាន កត់ត្រា និងគ្រប់គ្រងលើគណនីនីមួយៗបានយ៉ាងមានប្រសិទ្ធភាពផងដែរ។

ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងពង្រឹងការអនុវត្តមុខងារត្រួតពិនិត្យរបស់ខ្លួនលើប្រព័ន្ធទូទាត់ និងសេវាទូទាត់តាមរយៈការលើកកម្ពស់សមត្ថភាពមន្ត្រីត្រួតពិនិត្យ និងការសិក្សាស្វែងយល់អំពីឧត្តមានុវត្តភាពរបស់ប្រទេសក្នុងតំបន់ និងស្តង់ដាអន្តរជាតិ។ ការត្រួតពិនិត្យ មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតជំនឿទុកចិត្តរបស់អតិថិជនដោយកាត់បន្ថយហានិភ័យប្រព័ន្ធនិងសេវាទូទាត់ ទប់ស្កាត់ហានិភ័យជាប្រព័ន្ធ និងពង្រឹងការគោរពតាមក្របខណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ន។ ក្របខណ្ឌនៃការត្រួតពិនិត្យប្រព័ន្ធទូទាត់ត្រូវបានដាក់ឱ្យអនុវត្ត ហើយនីតិវិធីត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់កំពុងបន្តរៀបចំដើម្បីជាមូលដ្ឋានសម្រាប់ ពង្រឹងការត្រួតពិនិត្យឱ្យកាន់តែមានប្រសិទ្ធភាព។ ជាក់ស្តែង គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បានកើនឡើងគួរកត់សម្គាល់ដល់មានចំនួន ២៨ គ្រឹះស្ថាន។ ក្នុងនោះ ចំនួនប្រតិបត្តិការរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សង់ប្រាក់សរុបមាន ៥៨,៩ លានប្រតិបត្តិការ ស្មើនឹង ទំហំប្រាក់ចំនួន ៥,៦ ប៊ីលានដុល្លារអាមេរិក។ រីឯចំនួនភ្នាក់ងាររបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មានការកើនឡើងពី ២៥,៤ ពាន់ ដល់ ៣១,៦ ពាន់ភ្នាក់ងារ និងចំនួនអតិថិជនចុះឈ្មោះគណនីកាបូបអេឡិចត្រូនិចកើនពី ១,៣ លានគណនីនៅដំណាច់ឆ្នាំ២០១៩ ដល់ ៣,៦ លានគណនី នៅក្នុងឆ្នាំ២០២០ ។

ក្នុងក្របខណ្ឌអាស៊ាន ធនាគារជាតិនៃកម្ពុជា ជាសមាជិកនៃគណៈកម្មការប្រព័ន្ធទូទាត់អាស៊ាន និងបានចូលរួមរៀបចំ និងអនុវត្តផែនការសកម្មភាពជាយុទ្ធសាស្ត្រក្នុងការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់អាស៊ាន ដើម្បីរួមចំណែកទ្រទ្រង់ដល់សហគមសេដ្ឋកិច្ចអាស៊ាន។ ធនាគារជាតិនៃកម្ពុជា បានចូលរួមដាក់ឱ្យដំណើរការសេវាទូទាត់ឆ្លងដែនតាមរយៈ QR កូត រវាងប្រទេសកម្ពុជា និងប្រទេសថៃ និងកំពុងសិក្សាពីលទ្ធភាពភ្ជាប់ប្រព័ន្ធទូទាត់ជាមួយបណ្តាប្រទេសសមាជិកអាស៊ានផ្សេងៗទៀតតាមតម្រូវការ ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

### ១.២.៧. ប្រតិបត្តិការទីផ្សារអន្តរធនាគារ

អត្រាការប្រាក់លើមូលបត្រអាចជួញដូរបាន (NCD) និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ត្រូវបានកាត់បន្ថយ ដើម្បីរួមចំណែកជំរុញការផ្តល់ប្រាក់កម្ចីជារៀល។ NCD បានរួមចំណែកដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានសន្ទនីយភាពលើសក្នុងការគ្រប់គ្រងសន្ទនីយភាពឱ្យមានប្រសិទ្ធភាពខ្ពស់ ដែលក្នុងនោះការចេញផ្សាយ NCD ចារឹកជាដុល្លារអាមេរិកនិងជារៀល បានកើនឡើងដល់ ៣០,៨ ប៊ីលាន ដុល្លារអាមេរិក និង ១០,៩ ទ្រីលានរៀល (កំណើន ៩៥,៣% និង ៤,០%) រៀងគ្នា។ ចំណែកប្រតិបត្តិការ LPCO ក៏មានការកើនឡើង ២៤,៥% បើធៀបនឹងឆ្នាំ២០១៩ សរុបជាទឹកប្រាក់ប្រមាណ ៥,៩ ទ្រីលានរៀល និងត្រូវបានធ្វើឡើង ចំនួន ២៤លើកក្នុងឆ្នាំ២០២០ ដើម្បីបំពេញតម្រូវការសន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ប្រតិបត្តិការនេះក៏បានគាំទ្រដល់ការប្រើប្រាស់ប្រាក់រៀល និងវិស័យដែលប្រើប្រាស់ប្រាក់រៀលច្រើនជាពិសេស វិស័យកសិកម្ម។

## ២. ការវិវឌ្ឍនៃក្របខណ្ឌត្រួតពិនិត្យនិងបទប្បញ្ញត្តិ

### ២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ

#### ២.១.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិក្នុងឆ្នាំ២០២០

ក្នុងទិសដៅពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងសុខមាលភាពនៃប្រព័ន្ធធនាគារ ស្របតាមវឌ្ឍនភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា បានបង្កើតក្រុមឯកទេសវិភាគហានិភ័យ ដើម្បីសិក្សាលើហានិភ័យចំបងៗដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជួបប្រទះសំដៅដល់ការដាក់ចេញនូវវិធាន ឬ បទប្បញ្ញត្តិដែលទន់ភ្លន់ ប៉ុន្តែមានប្រសិទ្ធភាពខ្ពស់ ក្នុងការការពារហានិភ័យ។ តាមរយៈការពិនិត្យបទប្បញ្ញត្តិឡើងវិញ ធនាគារជាតិនៃកម្ពុជា បានលើកលែងកម្រិតកំណត់លើស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណដូចមានក្នុងប្រកាស ស្តីពី ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកអនុវត្តគោលនយោបាយ លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ស្របគ្នានេះ ក្នុងការលើកកម្ពស់ការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់ ការប្រកួតប្រជែងស្មើភាព និងការបង្កើនបរិយាបន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក៏បានធ្វើវិសោធនកម្មប្រកាស ស្តីពី ការចែករំលែកព័ត៌មានឥណទានឡើងវិញ សំដៅកាត់បន្ថយហានិភ័យឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

លើសពីនេះ ដើម្បីជំរុញការអនុវត្តប្រកាស ស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាស ស្តីពី អនុបាតក្របខណ្ឌសន្ទនីយភាពឱ្យមានប្រសិទ្ធភាពខ្ពស់ ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំ ស្តីពី សេចក្តីពន្យល់បន្ថែមទៅលើ ឧបសម្ព័ន្ធ ២ នៃប្រកាស ស្តីពី អនុបាតក្របខណ្ឌសន្ទនីយភាព និងសារាចរណែនាំបន្ថែមស្តីពី ការអនុវត្តប្រកាស ស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

#### ២.១.២. ការឆ្លើយតបផ្នែកបទប្បញ្ញត្តិចំពោះការរីករាលដាលនៃជំងឺកូវីដ-១៩

ក្នុងការចូលរួមគាំទ្រអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការ ដោះស្រាយបញ្ហាប្រឈមដែលបណ្តាលមកពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុទាន់ពេលវេលា និងជួយសម្រួលដល់អតិថិជនដែលរងផលប៉ះពាល់ ធនាគារជាតិនៃកម្ពុជា បានបន្ធូរបន្ថយការអនុវត្តបទប្បញ្ញត្តិមួយចំនួន ជាបណ្តោះអាសន្ន ដូចជា ១/- ពន្យាពេលឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរក្សាកម្រិតទ្រនាប់ដើមទុន ខនស៊ើវេសិន (CCB) ត្រឹម ៥០% ២/- កាត់បន្ថយអត្រាការប្រាក់អប្បបរមានៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ចំនួន ០,៥% ចំពោះគ្រប់ឥណទានប្រតិទាន ៣/- កាត់បន្ថយអត្រាការប្រាក់លើមូលបត្រ អាចជួញដូរបាន (NCD) ចារឹកជារៀល និងជាដុល្លារអាមេរិក ក្នុងកម្រិតសមស្រប ៤/- កាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ច (RRR) ពី ៨% ចំពោះប្រាក់រៀល និង ១២,៥% ចំពោះរូបិយប័ណ្ណ មកត្រឹម ៧% ទាំងចំពោះប្រាក់រៀលនិងរូបិយប័ណ្ណ

៥/- កាត់បន្ថយកម្រិតអនុបាតក្របខណ្ឌសន្ទនីយភាព (LCR) ក្នុងកម្រិតសមស្របតាមការចាំបាច់ និង ៦/- ការទទួលស្គាល់ប្រាក់ចំណេញក្នុងត្រីមាសដែលបានធ្វើសវនកម្មរួច សម្រាប់ដាក់បញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធជាដើម។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំស្តីពី ការរៀបចំឥណទានឡើងវិញ ចំពោះអតិថិជនស្ថិតក្នុងវិស័យអាទិភាពចំនួន ៤រួមមាន៖ ទេសចរណ៍ កាត់ដេរ សំណង់ និងការដឹកជញ្ជូន ព្រមទាំងបានពង្រីកវិសាលភាពដល់វិស័យផ្សេងៗដែលរងផលប៉ះពាល់។ ទន្ទឹមនេះ បទប្បញ្ញត្តិមួយចំនួនក៏ត្រូវបានដាក់ឱ្យប្រើប្រាស់រួមមាន៖

- ប្រកាសស្តីពីប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដោយតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតម្កល់ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីជាមធ្យមប្រចាំថ្ងៃនៅធនាគារជាតិនៃកម្ពុជា ស្មើនឹងអត្រា ៧% ចំពោះរូបិយវត្ថុជាតិនិងរូបិយប័ណ្ណ (លេខ ធ៧-០២០-២៣០ ប្រ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០)

- សារាចរណែនាំស្តីពីឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលរងផលប៉ះពាល់ពីការរីករាលដាលរបស់វីរុសកូវីដ-១៩ (លេខ ធ៧-០២០-០០១ ស.រ.ណ.ន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០)

- លិខិតស្តីពីការស្នើសុំការបន្ធូរបន្ថយលក្ខខណ្ឌមួយចំនួនពាក់ព័ន្ធនឹងឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលផលប៉ះពាល់ពីការរីករាលដាលរបស់ជំងឺកូវីដ-១៩ (លេខ ធ៧-០២០-១៧៤៨ ឆ.ត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០)

- លិខិតស្តីពី i/- ការកាត់បន្ថយកម្រិតទ្រនាប់ដើមទុនខនស៊ើវេសិន មកត្រឹម ១,២៥% និង ii/- ការទទួលស្គាល់ប្រាក់ចំណេញក្នុងត្រីមាសដែលបានធ្វើសវនកម្មរួច ក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធជាបណ្តោះអាសន្ន ដោយមិនមានការបែងចែកភាគលាភ (លេខ ធ៧-០២០-៦២២ ឆ.ត ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០)

- លិខិតស្តីពីសំណើសុំការអនុគ្រោះបន្ធូរបន្ថយកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងឥណទាន និង/ឬ លើកលែងការផាកពិន័យផ្សេងៗចំពោះអតិថិជន (លេខ ធ៧-០២០-៦៥៧ ឆ.ត ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០)

- ប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទានថ្មី (លេខ ធ៧-០២០-៣៥២ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០)

- សារាចរណែនាំបន្ថែមស្តីពីការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (លេខ ធ៧-០២០-០០២ ស.រ.ណ.ន ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០) និង

- សារាចរណែនាំស្តីពីសេចក្តីពន្យល់បន្ថែមទៅលើឧបសម្ព័ន្ធ ២ នៃប្រកាសស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព (លេខ ធ៧-០២០-០០៣ ស.រ.ណ.ន ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០)។

## ២.២. សកម្មភាពនៃការត្រួតពិនិត្យ

នៅក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ធនាគារជាតិនៃកម្ពុជា បាននិងបន្តតាមដានយ៉ាងយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់ចំពោះសុខុមាលភាព និងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បន្តពង្រីកការអនុវត្តច្បាប់និងបទប្បញ្ញត្តិ និងការអនុវត្តតាមវិធានការនានា។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បានអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និងរក្សាបានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តពង្រឹងរចនាសម្ព័ន្ធ និងអភិបាលកិច្ចរបស់ខ្លួនដូចជា លក្ខខណ្ឌ មុខងារភារកិច្ច និងការប្រតិបត្តិរបស់ក្រុមប្រឹក្សាភិបាល គណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាល មុខងារប្រតិបត្តិតាម និងការគ្រប់គ្រងហានិភ័យ ជាដើម។ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តផែនការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគតដែលក្នុងនោះបានរៀបចំកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យឡើងវិញ ដើម្បីជំរុញការត្រួតពិនិត្យកាន់តែមានប្រសិទ្ធភាព។ ការត្រួតពិនិត្យផ្អែកលើហានិភ័យ គឺការពិនិត្យស្ថានភាពទូទៅ សកម្មភាពចម្បងៗនៃអាជីវកម្ម ការវិភាគហានិភ័យ ការវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រង[1] ការពិនិត្យលើបញ្ហាប្រឈមនិងវិធានការដោះស្រាយ និងការវាយតម្លៃការអនុវត្តតាមច្បាប់ ប្រកាស និងបទប្បញ្ញត្តិប្រុងប្រយ័ត្នដែលបានដាក់ឱ្យអនុវត្ត។

លើសពីនេះ វិធីសាស្ត្រនៃការត្រួតពិនិត្យក៏បានរួមបញ្ចូលការធ្វើស្ត្រេសតេស្តអនុបាតក្របខណ្ឌសន្ទនីយភាព និងអនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីវាស់វែងពីភាពធន់នៃសន្ទនីយភាព និងដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។

ហេតុដូច្នេះ ការត្រួតពិនិត្យដល់ទីកន្លែងបានផ្តោតការយកចិត្តទុកដាក់អភិបាលកិច្ច ការរៀបចំឥណទានឡើងវិញ គុណភាពទ្រព្យសកម្ម ហានិភ័យឥណទាន និងហានិភ័យព័ត៌មានវិទ្យា ជាដើម។ ជាលទ្ធផល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួននៅមានបញ្ហាប្រឈម ដូចជា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងប្រព័ន្ធព័ត៌មានវិទ្យានៅមានកម្រិត បញ្ហាប្រភពទុនដោយសារភាគទុនិកមានភាពយឺតយ៉ាវក្នុងការផ្តល់ទុនបន្ថែមនៅពេលមានវិបត្តិជាសកល ការយល់ដឹងពុំទាន់គ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងការអនុវត្តតាមបទប្បញ្ញត្តិមាន ដូចជា ការអនុវត្តតាមប្រកាស ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមែន ការអនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ និងការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូចនិងមធ្យម។ បញ្ហាប្រឈមទាំងនេះ ត្រូវបានផ្តល់អនុសាសន៍ឱ្យកែសម្រួល និងតាមដានវឌ្ឍនភាពការអនុវត្តជាប្រចាំ។ ធនាគារជាតិនៃកម្ពុជា បន្តពង្រឹងគុណភាពទិន្នន័យក្នុងរបាយការណ៍ហិរញ្ញវត្ថុ

[1] ផ្នែកប្រតិបត្តិតាម ផ្នែកគ្រប់គ្រងហានិភ័យ និងផ្នែកត្រួតពិនិត្យផ្ទៃក្នុង។

របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈកិច្ចប្រជុំអនឡាញជាមួយគ្រឹះស្ថាន ដើម្បីបង្ហាញនូវកំហុសឆ្គង និងផ្តល់ការណែនាំរកដំណោះស្រាយទាន់ពេលវេលា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ពិន័យអន្តរការណ៍ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមិនគោរពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ជារួម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅតែរក្សាបានភាពរឹងមាំដែលឆ្លុះបញ្ចាំងតាមរយៈសន្ទនីយភាពគ្រប់គ្រាន់ អនុបាតសាធនភាពខ្ពស់ជាង កម្រិតកំណត់អប្បបរមាកំណត់ ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ជាមួយនឹងប្រសិទ្ធភាពនៃអភិបាលកិច្ចនិងការត្រួតពិនិត្យផ្ទៃក្នុង និងការរក្សាបាននូវប្រាក់ចំណេញ។

## ២.៣. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ

ស្ថិតនៅក្រោមបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ វិស័យអចលនទ្រព្យនៅកម្ពុជាជារួមមិនទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ បើធៀបទៅនឹងវិស័យសំខាន់ៗមួយចំនួនផ្សេងទៀតក្នុងសេដ្ឋកិច្ច ដូចជា កសិកម្ម និងទេសចរណ៍ ជាដើម។ ចំណែកទីផ្សារឥណទានរបស់ប្រព័ន្ធធនាគារចំពោះវិស័យអចលនទ្រព្យមាន ២៦,៣% នៃសំពៀតឥណទានសរុប ក្នុងនោះការផ្តល់ឥណទានចំពោះវិស័យអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារ ៩៧,៣% គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២,៥% និងក្រុមហ៊ុនភតិសន្យា ០,២%។ ឥណទានចំពោះវិស័យអចលនទ្រព្យ សំដៅដល់ការផ្តល់ឥណទានទៅសកម្មភាពអចលនទ្រព្យ សំណង់ និងការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ដែលក្នុងនោះ កំណើនឥណទានទៅលើសកម្មភាពអចលនទ្រព្យ ២១,២% សំណង់ ២៥,៣% និងការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ២៦,០%។ ដោយសារវិស័យអចលនទ្រព្យនៅកម្ពុជាមានការកើនឡើងយ៉ាងឆាប់រហ័ស និងបន្តមានភាពពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជា បាននិងបន្តយកចិត្តទុកដាក់ត្រួតពិនិត្យ និងតាមដានលើវឌ្ឍនភាពនៃឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទៅកាន់វិស័យនេះជាប្រចាំ។

រូបភាព១៥៖ ចំណែកទីផ្សារឥណទានទៅវិស័យអចលនទ្រព្យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ទិន្នន័យក្នុងប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) បានបង្ហាញថា លំហូរទុនវិនិយោគផ្ទាល់បរទេសក្នុងវិស័យអចលនទ្រព្យ (រួមបញ្ចូលនូវគ្រប់ប្រភេទអចលនទ្រព្យនិងខុនដូ) នៅកម្ពុជាក្នុងឆ្នាំ២០២០ មាន ១.៨៣៨,២ ប៊ីលានរៀល (៣៥៥,៦ លានដុល្លារអាមេរិក) រួមមាន ប្រទេសចិន ៤៩,៦% ប្រទេសសិង្ហបុរី ៣២,២% និងប្រទេសផ្សេងៗទៀតមាន ១៨,២% នៃការវិនិយោគសរុប។

តារាង៤៖ ការវិនិយោគក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា — គិតជាប៊ីលានរៀល

| | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| ការវិនិយោគជាដើមទុននៅកម្ពុជា | ១០.០៤១ | ១១.២៨៤ | ១២.៥៥០ | ១៤.៩៩១ | ១៤.៦៦២ |
| ការវិនិយោគក្នុងវិស័យអចលនទ្រព្យ | ១.២៦៨ | ១.៨៨៩ | ១.៨៧៤ | ១.៧៨២ | ១.៨៣៨ |

ប្រភព ៖ ការប៉ាន់ស្មានក្នុងប្រព័ន្ធ ITRS (International Transaction Reporting System) របស់ ធនាគារជាតិនៃកម្ពុជា

រូបភាព១៦៖ លំហូរចូលនៃការវិនិយោគផ្ទាល់បរទេសក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា




ប្រភព ៖ ប្រព័ន្ធ ITRS របស់ធនាគារជាតិនៃកម្ពុជា

ទន្ទឹមនេះធនាគារជាតិនៃកម្ពុជា បានបន្តប្រមូលទិន្នន័យពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពក្នុងការរាយការណ៍គុណភាពទិន្នន័យ និងការគណនាសូចនាករសន្ទស្សន៍ថ្លៃអចលនវត្ថុ (Property Pricse Index)។ សូចនាករសន្ទស្សន៍ថ្លៃអចលនវត្ថុនឹងផ្តល់នូវព័ត៌មានសំខាន់ស្តីពីវឌ្ឍនភាព និងទិដ្ឋភាពទូទៅនៃទីផ្សារអចលនវត្ថុ ដែលនឹងជួយដល់ធនាគារជាតិនៃកម្ពុជាក៏ដូចជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យ។

រូបភាព១៧៖ ឥណទានទៅវិស័យអចលនទ្រព្យ




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់

### ៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ

#### ៣.១.១. ស្តង់ដាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា បានរៀបចំរួចរាល់នូវប្លង់គណនីឯកភាពនិងសៀវភៅណែនាំ ស្តីពីការប្រើប្រាស់ប្លង់គណនីឯកភាព និងបានធ្វើបច្ចុប្បន្នកម្មទម្រង់របាយការណ៍ប្រចាំខែមួយចំនួន ឱ្យស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) ដែលរបាយការណ៍ទាំងនោះ រួមមាន៖ ១/- របាយការណ៍ប្រចាំខែ ស្តីពីទ្រព្យសកម្មនិងទ្រព្យអកម្ម ២/- របាយការណ៍ស្តីពីចំណូលនិងចំណាយ ៣/- របាយការណ៍ ស្តីពីប្រាក់ចំណូលលម្អិតផ្សេងទៀត និង ៤/- របាយការណ៍ស្តីពីក្រៅតារាងតុល្យការ។ ជំនួសឱ្យការរៀបចំសិក្ខាសាលាក្នុងអំឡុងពេលជំងឺកូវីដ-១៩ ធនាគារជាតិនៃកម្ពុជា បានផ្ញើសេចក្តីព្រាងប្លង់គណនីឯកភាពនិងសៀវភៅណែនាំឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ គ្រឹះស្ថានឥណទានជនបទនិងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ផ្តល់មតិយោបល់និងសំណួរផ្សេងៗ និងបានដាក់ឱ្យគ្រឹះស្ថានខាងលើប្រើប្រាស់ជាផ្លូវការនូវប្លង់គណនីឯកភាព សៀវភៅណែនាំស្តីពីការប្រើប្រាស់ប្លង់គណនីឯកភាពនិងទម្រង់របាយការណ៍ទាំងនេះ ដោយគ្រឹះស្ថានត្រូវចាប់ផ្តើមប្រើប្រាស់ទម្រង់របាយការណ៍ថ្មី

នេះទទឹមគ្នានឹងរបាយការណ៍ចាស់ ដើម្បីរាយការណ៍មកធនាគារជាតិនៃកម្ពុជា ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២០តទៅ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា បាននិងកំពុងរៀបចំគោលការណ៍ណែនាំ ស្តីពី ការកំណត់តម្លៃទ្រព្យធានា ក្នុងគោលបំណងគណនាសំវិធានធនតាមស្តង់ដា CIFRS ៩ ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២១។

ជាមួយគ្នានេះ ស្ថិតក្នុងផ្នែកមួយនៃដំណើរផ្លាស់ប្តូរឆ្ពោះទៅរកការអនុវត្តការត្រួតពិនិត្យផ្អែកលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត គិតត្រឹមដំណាច់ឆ្នាំ២០២០នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចជោគជ័យក្នុងការសាកល្បងដំណាក់កាលទី១ នៃការរៀបចំសេចក្តីណែនាំស្តីពីការបញ្ចូល និងការផ្ទៀងផ្ទាត់របាយការណ៍ និងការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាដែលគាំទ្រដល់ការត្រួតពិនិត្យផ្អែកលើហានិភ័យ។ សេចក្តីណែនាំស្តីពីការបញ្ចូល និងការផ្ទៀងផ្ទាត់មានរបាយការណ៍ចំនួន ៦ ដូចជា៖ ១/-របាយការណ៍ ស្តីពី ទ្រព្យសកម្មនិងទ្រព្យអកម្ម ២/- របាយការណ៍ ស្តីពី ចំណូលនិងចំណាយ ៣/-របាយការណ៍ ស្តីពី ក្រៅតារាងតុល្យការ ៤/- របាយការណ៍ ស្តីពី ឥណទានតាមប្រភេទជំនួញ និងម្ចាស់កម្មសិទ្ធិក្នុងវិស័យសេដ្ឋកិច្ច ៥/- របាយការណ៍ ស្តីពី ប្រាក់បញ្ញើចំណាត់ថ្នាក់តាមប្រភេទអតិថិជន និងរូបិយបណ្ណ និង ៦/-របាយការណ៍ ស្តីពី ប្រាក់បញ្ញើចំណាត់ថ្នាក់តាមប្រភេទគណនីនិងទំហំទឹកប្រាក់។

**ប្រអប់១៖ ផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ មកលើប្រព័ន្ធធនាគារនៅកម្ពុជា និងយន្តការឆ្លើយតប ព្រមទាំងភាពធន់ឧត្តភាព**

នៅក្នុងឆ្នាំ២០២០ នេះ វិបត្តិជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងខ្លាំងលើសេដ្ឋកិច្ចសកលដែលក្នុងនោះរួមមានទាំងសេដ្ឋកិច្ចកម្ពុជាផងដែរ។ ទន្ទឹមនេះ ប្រព័ន្ធធនាគារនៅកម្ពុជាក៏ទទួលរងនូវផលប៉ះពាល់ដោយសារកូវីដ-១៩ នេះផងដែរ គ្រាន់តែផលប៉ះពាល់មានកម្រិតមធ្យមនិងអាចគ្រប់គ្រងបាន។ ឥណទានដែលបានរៀបចំឡើងវិញនៅក្នុងប្រព័ន្ធធនាគារទាំងមូលមានប្រមាណ ១០,៦% នៃឥណទានសរុប ហើយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅតែអាចរក្សាអនុបាតឥណទានមិនដំណើរការក្នុងកម្រិតទាប ដែលមានប្រមាណ ២,១% សម្រាប់គ្រឹះស្ថានធនាគារ និង ១,៨% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ បើទោះយ៉ាងនេះក៏ដោយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅតែអាចអនុលោមបានយ៉ាងខ្ជាប់ខ្ជួននូវអនុបាតប្រុងប្រយ័ត្ន និងតាមច្បាប់និងបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា។

ទន្ទឹមគ្នានេះ ធនាគារជាតិនៃកម្ពុជា បានចាត់វិធានការណ៍ឆ្លើយតប និងយន្តការការពារអតិថិជនដែលរួមមានទាំងវិធានបទប្បញ្ញត្តិ (ដូចមាន រៀបរាប់ក្នុងចំណុច ២.១.២ បទប្បញ្ញត្តិ) និងវិធានការណ៍ពង្រឹង ការតាមដាន ការវិវត្តនៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ដូចជា៖ ១/- ការប្រមូលទិន្នន័យបន្ថែមទាក់ទងនឹងវិស័យដែលរងផលប៉ះពាល់ដោយសារកូវីដ-១៩ និងទំហំឥណទានដែលបានរងផលប៉ះពាល់ ២/- ការប្រើប្រាស់វិធីសាស្ត្រវិភាគលម្អិតលើសូចនាករសំខាន់ៗដែលបង្ហាញពីស្ថានភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង ៣/- ការធ្វើ Simulation ទៅលើប្រាក់បម្រុងកាតព្វកិច្ច សាធនភាព និងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងការបន្ធូរបន្ថយកម្រិតបទប្បញ្ញត្តិដើម្បីឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានលទ្ធភាពបន្ត និងពង្រីកការផ្តល់ហិរញ្ញប្បទាន គាំទ្រដល់វិស័យរូបវន្ត (Real Sector) ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។

ស្របគ្នានឹងផលប៉ះពាល់ជាអវិជ្ជមានដែលកំពុងតែកើតមានឡើង ជំងឺកូវីដ-១៩ ក៏បាននាំមកនូវកាលានុវត្តភាពដល់ប្រព័ន្ធធនាគារនៅកម្ពុជា ជាពិសេសគឺ ការកើនឡើងនៃការទូទាត់ដោយប្រើប្រាស់សាច់ប្រាក់អេឡិចត្រូនិក ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួនអ្នកប្រើប្រាស់កាបូបអេឡិចត្រូនិក (E-wallet) ប្រមាណ ១៧៧% ពី ១,៣ លានគណនី ក្នុងឆ្នាំ២០១៩ ដល់ ៣,៦ លានគណនី ក្នុងឆ្នាំ២០២០ ដែលក្នុងនោះចំនួនប្រតិបត្តិការបានកើនឡើងដល់ ៥៨,៩ លានប្រតិបត្តិការ គិតជាទឹកប្រាក់មានទំហំ ៥,៦ ប៊ីលានដុល្លារអាមេរិក។

ជារួមប្រព័ន្ធធនាគារនៅកម្ពុជានៅតែអាចរក្សាបាននូវភាពធន់ និងរឹងមាំដែលអាចមានលទ្ធភាពទប់ទល់នឹងវិបត្តិជំងឺកូវីដ-១៩នេះ និងគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ។

### ៣.១.២. ការចែករំលែកព័ត៌មានឥណទាន

ក្រុមហ៊ុនសេវាចែករំលែកព័ត៌មានឥណទាន មានទ្រព្យសកម្មសរុបប្រមាណ ៦១,១ ប៊ីលានរៀល និងមានគ្រឹះស្ថានជាសមាជិកក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានចំនួន ១៦៨ ក្នុងនោះ៖ ធនាគារពាណិជ្ជ ៥៤ ធនាគារឯកទេស ១២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៣ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥ និងគ្រឹះស្ថានឥណទានជនបទ ៨។

រូបភាព១៨៖ គ្រឹះស្ថានជាសមាជិករបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សំពៀតឥណទានសរុបដែលគ្រឹះស្ថានជាសមាជិកបានបញ្ចូលនិងចែករំលែកនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មានចំនួនសរុប ១៥២,៤ ទ្រីលានរៀល (៣៧,៧ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៣,៥ លានគណនី ក្នុងនោះ ១/- ឥណទានឯកត្តបុគ្គលមានចំនួន ១២៩,៨ ទ្រីលានរៀល (៣២,១ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៣,៥ លានគណនី និង ២/- ឥណទានក្រុមហ៊ុនមានចំនួន ២២,៦ ទ្រីលានរៀល (៥,៦ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៥.៣៨៥ គណនី។

រូបភាព១៩៖ សំពៀតឥណទាននិងចំនួនគណនីបែងចែកតាមប្រភេទឥណទាន




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទន្ទឹមនេះ សំពៀតឥណទានសរុបត្រូវបានបញ្ចូលដោយប្រភេទគ្រឹះស្ថានជាសមាជិកនីមួយៗ រួមមាន៖ ធនាគារ ១២៣,៥ ទ្រីលានរៀល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២៧,៥ ទ្រីលានរៀល ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១,៤ ទ្រីលានរៀល និង គ្រឹះស្ថានឥណទានជនបទ ០,០៥ ទ្រីលានរៀល។

រូបភាព២០៖ សំពៀតឥណទានសរុបបែងចែកតាមប្រភេទគ្រឹះស្ថានជាសមាជិក




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

គ្រឹះស្ថានជាសមាជិកបានចូលពិនិត្យរបាយការណ៍ឥណទាន សរុបមានចំនួន ៤,៩ លានប្រតិបត្តិការ ក្នុងនោះ ធនាគារ ១,៥ លានប្រតិបត្តិការ ស្មើនឹង ៣០,៣% គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣,៣ លានប្រតិបត្តិការ ស្មើនឹង ៦៦,៨% ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៣០.០០៣ ប្រតិបត្តិការ ស្មើនឹង ២,៦% និងគ្រឹះស្ថានឥណទានជនបទ ១៥.៧៣៧ ប្រតិបត្តិការ ស្មើនឹង ០,៣% ។

រូបភាព២១៖ ការពិនិត្យរបាយការណ៍ឥណទានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា បានដាក់ចេញជាថ្មីនូវប្រកាស ស្តីពី ការចែករំលែកព័ត៌មានឥណទាន ក្នុងខែមិថុនា ឆ្នាំ២០២០ បន្ទាប់ពីបានធ្វើការកែសម្រួលរួចរាល់ក្នុងគោលបំណងបន្ថែមក្របខណ្ឌគតិយុត្តលើការវិវឌ្ឍនៃប្រតិបត្តិការចែករំលែកព័ត៌មានឥណទាន តាមរយៈការចែករំលែកព័ត៌មានឥណទានឆ្លងប្រទេសក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការដោយត្រូវមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា និងព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដំណើរការកម្មវិធីទូរស័ព្ទ (CBC Mobile App) សម្រាប់សាកល្បង និងដាក់ឱ្យដំណើរការជាផ្លូវការក្នុងខែតុលា ឆ្នាំ២០២០ ក្នុងគោលបំណង ១/- អតិថិជនអាចត្រួតពិនិត្យរបាយការណ៍ ឥណទានផ្ទាល់ខ្លួន ២/- ប្រមូលផ្តុំទៅដោយឯកសារអប់រំពាក់ព័ន្ធនឹងចំណេះដឹងហិរញ្ញវត្ថុ និង ៣/- ទទួលបានព័ត៌មានសំខាន់ផ្សេងៗពីអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ ដើម្បីពង្រឹងគុណភាព និងតម្លាភាពនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ធនាគារជាតិនៃកម្ពុជា បន្តត្រួតពិនិត្យអ្នកផ្តល់សេវា និងសមាជិកនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ក៏ដូចជាដាក់ចេញនូវវិធានការចាំបាច់នានា។

## ៣.២. ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា

បរិយាបន្នហិរញ្ញវត្ថុ បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការបង្កើនសមភាព និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ហើយក៏ជាឧបករណ៍គោលនយោបាយដ៏សំខាន់សម្រាប់អ្នករៀបចំគោលនយោបាយ ទាំងថ្នាក់ជាតិ និងថ្នាក់សកល។ រាជរដ្ឋាភិបាលកម្ពុជា ក៏បាននិងកំពុងយកចិត្តទុកដាក់ក្នុងការបង្កើនកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ក្នុងគោលបំណងជំរុញលទ្ធភាពរបស់ប្រជាជនទូទៅឱ្យទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ ទាន់ពេលវេលា មានតម្លៃសមស្រប និងមានកិច្ចគាំពារតាមផ្លូវច្បាប់ ព្រមទាំងលើកទឹកចិត្តឱ្យប្រជាជនដែលប្រើប្រាស់

សេវាហិរញ្ញវត្ថុក្រៅផ្លូវការ ប្ដូរមកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដែលមានការត្រួតពិនិត្យត្រឹមត្រូវពីអាជ្ញាធរត្រួតពិនិត្យ។

ក្នុងន័យនេះ យុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ បានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងគោលដៅបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព និងការពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី ៥៩% ទៅ ៧០% និងកាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុពី ២៧% មកត្រឹម ១៣% តាមរយៈសកម្មភាពអាទិភាពចំនួន ៦ រួមមាន៖

១/- លើកទឹកចិត្តឲ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ

២/- ជំរុញនវានុវត្តន៍សេវាឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម

៣/- ពង្រីកសមត្ថភាពប្រព័ន្ធទូទាត់

៤/- ពង្រីកការផ្ដល់សេវាធានារ៉ាប់រងឲ្យបានទូលំទូលាយ

៥/- ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ និង

៦/- លើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យ ហិរញ្ញវត្ថុ។

ដើម្បីគាំទ្រដល់សកម្មភាពអាទិភាពទាំង ៦ នេះ ផែនការសកម្មភាពចំនួន ១១៥ ត្រូវបានកំណត់និងបែងចែកទៅតាមស្ថាប័នដែលពាក់ព័ន្ធដើម្បីអនុវត្ត ដែលនៅក្នុងនោះ ធនាគារជាតិនៃកម្ពុជាជាស្ថាប័នដឹកនាំផែនការសកម្មភាពចំនួន ៥៨ រួមមាន ផែនការរយៈពេលខ្លីចំនួន ២២ រយៈពេលមធ្យមចំនួន ២៧ និងរយៈពេលវែងចំនួន ៩។ បន្ទាប់ពីយុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុត្រូវបានអនុម័ត ធនាគារជាតិនៃកម្ពុជា បានបំពេញផែនការសកម្មភាពអាទិភាពមួយចំនួនដោយជោគជ័យ និងចាប់ផ្ដើមអនុវត្តផែនការសកម្មភាពអាទិភាពផ្សេងទៀតជាបន្តបន្ទាប់។

### ៣.២.១. ការអប់រំផ្នែកហិរញ្ញវត្ថុ

#### ៣.២.១.១. សិក្ខាសាលាផ្សព្វផ្សាយអំពីវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

